ភ្នំពេញ , ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្ដីសម្រេច លេខ ១៥ សសរ
## ស្ដីពីមុខងារ និង ភារកិច្ចរបស់
## ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ

* * *

- បានឃើញក្រឹត្យស្ដីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជារបស់សម្ដេចព្រះឧបយុវរាជ នរោត្ដម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- ផ្អែកតាមសភាពការណ៍ចាំបាច់ នៃការងារប្រទេសជាតិ

## សម្រេច

**ប្រការ ១ :** ប្រគល់ភារកិច្ចជូនឯកឧត្តម វណ្ណ ម៉ូលីវណ្ណ ទេសរដ្ឋមន្ត្រីនៃសហប្រធាន រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន នៃកម្ពុជា ដូចតទៅ ÷

១- ត្រួតពិនិត្យ និង តាមដានកិច្ចការវប្បធម៌ និងវិចិត្រសិល្បៈជាពិសេសមាធ្យោបាយការពារ បេតិកភ័ណ្ឌជាតិ ។

២- ត្រួតពិនិត្យ និង តាមដានការអភិវឌ្ឍន៍ កន្លែងទេសចរនៅតាមឆ្នេរសមុទ្រ និងការពារបរិដ្ឋាន ។

៣- ត្រួតពិនិត្យ និង តាមដានកិច្ចការរៀបចំកែលំអទីក្រុងភ្នំពេញ និង ខេត្តទូទាំងប្រទេស

**ប្រការ ២ :** ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ មានសិទ្ធិជ្រើសរើសបុគ្គលិកមួយចំនួនដែលមានគ្រប់ខ័ណ្ឌរដ្ឋស្រាប់ដើម្បីជាជំនួយការ ។

**ប្រការ ៣ :** ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ មានសិទ្ធិអញ្ជើញបណ្ដាមន្ត្រី និយោជិត នៅតាមក្រសួង និង ខេត្ត ក្រុង ដែលពាក់ព័ន្ធមកប្រជុំពិភាក្សាដោះស្រាយ រាល់ភារកិច្ចដែលមានចែងក្នុងប្រការ ១ ។

**ប្រការ ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារ និង សាធារណៈ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសាធារណការ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងបរិដ្ឋាន បណ្ដាក្រសួងដែលមានពាក់ព័ន្ធ

អភិបាល គ្រប់ខេត្ត ក្រុង ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ មានភារកិច្ចអនុវត្តសេចក្តីសំរេច នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * * * *

ភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ ១៦ សសរ

## ស្តីពីការចាត់តាំងគណៈកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ អន្តរជាតិទទួល និង ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ ជាតិ និង អន្តរជាតិជាផ្លូវការ

* * *

## រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា
- ផ្អែកតាមសំណូមពរចាំបាច់

## សំរេច

ប្រការ ១ : ចាត់តាំងគណៈកម្មការ អចិន្ត្រៃយ៍ អន្តរក្រសួង ជាសេនាធិការ អោយរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជាទទួលបន្ទុក ដឹកនាំនិងទទួលខុសត្រូវ ក្នុងការរៀបចំបុណ្យជាតិ អន្តរជាតិធំៗ និង ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ជាតិ ... អន្តរជាតិជាផ្លូវការផង